# ព្រឹត្តិបត្រ ស្តីពីបញ្ហាអាជីវកម្ម

កម្ពុជា

លេខ ១៣, មីនា ២០០៧




## ចំណាយក្រៅផ្លូវការ រារាំងការរីកចំរើននៃអាជីវកម្ម ក្នុងប្រទេសកម្ពុជា

*ប្រទេសកម្ពុជាពឹងផ្អែកលើផ្នែកឯកជន ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងបង្កើតការងារ ប៉ុន្តែចំណាយក្រៅផ្លូវការដ៏ខ្ពស់ បានធ្វើឱ្យការធ្វើអាជីវកម្មនៅកម្ពុជាជួបការលំបាក ។ អាជីវកម្មទាំងឡាយតែងតែរាយការណ៍ថា ចំណាយក្រៅផ្លូវការ គឺជាបញ្ហាចំបងមួយដែលបន្ទចបង្អាក់ពួកគេ មិនឱ្យរីកលូតលាស់បាន ។ ចំណាយក្រៅផ្លូវការ បង្កឱ្យមានផលអវិជ្ជមាន ចំពោះសេដ្ឋកិច្ច ដោយរារាំងមិនឱ្យផ្នែកឯកជនអាចពង្រីកសកម្មភាពរបស់ខ្លួន និងបង្កើតការងារ ។*

*ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០៦* [១] *បានវាស់ ចំណាយក្រៅផ្លូវការនៅតាមខេត្តចំនួន ១០ និងបានរកឃើញថា ទោះបីចំណាយក្រៅផ្លូវការមានកំរិតខុសៗគ្នា ទៅតាមខេត្តផ្សេងៗគ្នាក្តី វាតែងធ្វើឱ្យអាជីវកម្មខាតបង់នៅគ្រប់ទិសទី ។ ដោយមានព័ត៌មានអំពីកំរិតនៃចំណាយក្រៅផ្លូវការនៅតាមខេត្ត អាជ្ញាធរថ្នាក់ខេត្តទាំងឡាយមានឱកាសសម្រាប់ធ្វើសកម្មភាពកែលំអអភិបាលកិច្ចសេដ្ឋកិច្ចរបស់ខ្លួន និងពិនិត្យតាមដានការអនុវត្តន៍ នៅក្នុងឆ្នាំនីមួយៗ ។*

*ព័ត៌មានដ៏ល្អបានមកពីការអង្កេតនៃការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនេះ បង្ហាញថា ការកាត់បន្ថយចំណាយក្រៅផ្លូវការនឹងធ្វើឱ្យបរិយាកាសអាជីវកម្មល្អប្រសើរឡើង ។ ជាលទ្ធផលផ្នែកឯកជនរឹងមាំជាងមុន ហើយនឹងជួយបង្កើតការងារបានច្រើនជាងមុន ។*

*គេឃើញមានវិធានការរយៈពេលខ្លីល្អៗមួយចំនួន ដែលខេត្តផ្សេងៗអាចអនុវត្តបាន ដើម្បីកាត់បន្ថយចំណាយ ក្រៅផ្លូវការ ។ ជាពិសេសការសម្រួល និងការកែលំអបែបបទរដ្ឋបាល គឺជាវិធានការដ៏មានប្រសិទ្ធភាពខ្ពស់ ព្រោះការកែលំអតម្លាភាព និងការកាត់បន្ថយភាពស្មុគស្មាញនៃការិយាធិបតេយ្យ អាចបំបាត់ឱកាសសម្រាប់ឱ្យមន្ត្រីទាំងឡាយទារថ្លៃឈ្នួលក្រៅផ្លូវការបាន ព្រមទាំងលុបបំបាត់ចោលនូវកត្តាជំរុញផ្សេងៗដែលនាំឱ្យអាជីវកម្មទាំងឡាយបង់ចំណាយទាំងនោះ ។ បច្ចុប្បន្ន កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC-MPDF) កំពុងធ្វើការជាមួយអាជ្ញាធរខេត្តមួយចំនួនលើគម្រោងកែសម្រួលបែបបទរដ្ឋបាល ដើម្បីជួយពួកគេឱ្យសម្រេចគោលដៅនេះបាន ។*

*ទីបំផុត នៅពេលដែលគេកាត់បន្ថយចំណាយក្រៅផ្លូវការនេះបាន មនុស្សគ្រប់រូបនឹងទទួលបានផលប្រយោជន៍ ។ ផ្នែកឯកជនអាចរីកលូតលាស់បានល្អប្រសើរជាងមុន ហើយការណ៍នេះនឹងនាំឱ្យមានការងារធ្វើច្រើនជាងមុន និងមានប្រាក់ចំណូលច្រើនជាងមុននៅក្នុងសហគមន៍ ។ ព្រមគ្នានេះ ប្រាក់ចំណូលរបស់រដ្ឋាភិបាលក៏កើនឡើងដែរ នៅពេលដែលផ្នែកឯកជនរីកចម្រើន និងអាជីវកម្មរីកលូតលាស់ ។*

## តើ "ចំណាយក្រៅផ្លូវការ" ជាអ្វី?

ចំណាយក្រៅផ្លូវការ គឺជាការបង់ប្រាក់ក្រៅផ្លូវការជាបន្ថែម ទៅឱ្យមន្ត្រីរដ្ឋាភិបាល ដើម្បីទទួលបានផលប្រយោជន៍បែបណាមួយសម្រាប់បុគ្គល ឬអាជីវកម្ម ។ ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តក្នុងប្រទេសកម្ពុជា បានរកឃើញថា ចំណាយក្រៅផ្លូវការ ក្នុងប្រទេសកម្ពុជាមានពីរកម្រិត ពោលគឺ កម្រិតតូចតាច និង កម្រិតធំ ។

**ព្រឹត្តិបត្រស្តីពីបញ្ហាអាជីវកម្ម** ផ្តល់ជូនលោកអ្នកដែលមានចំណាប់អារម្មណ៍ពីរឿងរ៉ាវទាក់ទិននឹងកិច្ចការអាជីវកម្មនូវសេចក្តីសង្ខេបខ្លីៗ និងសេចក្តីវិភាគលើប្រធានបទដែលពាក់ព័ន្ធនឹងបរិយាកាសអាជីវកម្មនៅកម្ពុជា ។ ព្រឹត្តិបត្រនេះមានរួមបញ្ចូលទាំងមតិ និងយោបល់ផ្សេងៗ របស់មជ្ឈដ្ឋានពាក់ព័ន្ធផងដែរ ។

ព្រឹត្តិបត្រនេះ ត្រូវបានបោះពុម្ពឡើងដោយមានការឧបត្ថម្ភពីសំណាក់អង្គការកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ដែលជាស្ថាប័នពហុជំនួយគ្រប់គ្រងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាផ្នែកឯកជននៃក្រុមធនាគារពិភពលោក ។

មតិ ឬយោបល់ទាំងឡាយដែលចុះផ្សាយនៅក្នុងព្រឹត្តិបត្រនេះ មិនតំណាងឱ្យទស្សនៈជាផ្លូវការ របស់អង្គការកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ ឬ IFC ទេ វាគ្រាន់តែផ្តល់ជាព័ត៌មានយោងបន្ថែមតែប៉ុណ្ណោះ ។

---

[១] បើគ្មានកំណត់សំគាល់ផ្សេងទេ ព័ត៌មានទាំងឡាយដែលមាននៅក្នុង *ព្រឹត្តិប័ត្រ* នេះ ទាំងស្ថិតិ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ សុទ្ធតែដកស្រង់ចេញមកពី *ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តក្នុងប្រទេសកម្ពុជា: ការវាស់ស្ទង់ អភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយបទបញ្ញត្តិ*(PBES) ។ ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តក្នុងប្រទេសកម្ពុជា បានវាស់ស្ទង់ និងចាត់ថ្នាក់ អភិបាលកិច្ចសេដ្ឋកិច្ចនៃខេត្តកម្ពុជាចំនួន ១០ ដែលមានសកម្មភាពសេដ្ឋកិច្ចខ្ពស់ជាងគេ ដោយផ្អែកលើសូចនាករ ចំនួន ១០ ហើយចំណាយក្រៅផ្លូវការ គឺជាសូចនាករមួយនៃសូចនាករទាំងនោះ ។ ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត ក្នុងប្រទេសកម្ពុជា ដែលបោះពុម្ពផ្សាយក្នុងខែ មីនា ឆ្នាំ២០០៧ ជាកិច្ចសហប្រតិបត្តិការរបស់កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC-MPDF) និងមូលនិធិអាស៊ី (ដែលទទួលបានមូលនិធិ ពីទីភ្នាក់ងារអូស្ត្រាលីសំរាប់អភិវឌ្ឍន៍អន្តរជាតិ AusAID) ។

## ចំណាយក្រៅផ្លូវការខ្នាតតូច

នៅកម្រិតតូចតាច អាជីវករបង់សំណូកបន្តិចបន្តួចឱ្យមន្ត្រីរដ្ឋាភិបាល ដើម្បីទទួលបានសេចក្តីសម្រេចផ្លូវការដែលមានលក្ខណៈអនុគ្រោះចំពោះគេ ដើម្បីជំរុញបែបបទការិយាធិបតេយ្យ និងដើម្បីឆ្លងឱ្យផុតអធិការកិច្ចនៃបទបញ្ញត្តិផ្សេងៗ ។ ចំណាយក្រៅផ្លូវការបន្តិចបន្តួចជា "ថ្លៃឈ្នួលក្រៅផ្លូវការ" ធម្មតា ដែលអាជីវកម្មជាច្រើននៅកម្ពុជាត្រូវបង់ ដើម្បីទទួលបានលទ្ធផលសមតាមបំណងរបស់ខ្លួន ក្នុងពេលធ្វើការជាមួយមន្ត្រីរដ្ឋាភិបាល ។

គេសង្កេតឃើញមានកត្តាមួយចំនួន ដែលរួមចំណែកធ្វើឱ្យចំណាយក្រៅផ្លូវការមានកម្រិតខ្ពស់នៅកម្ពុជា ។ មន្ត្រីជាច្រើនទទួលបានប្រាក់ខែទាបដែលនាំឱ្យពួកគេទាមទារថ្លៃឈ្នួលក្រៅផ្លូវការបន្តិចបន្តួចសម្រាប់ជាប្រាក់ចំណូលបន្ថែមសំរាប់ពួកគេនៅពេលអនុវត្តការងារ ។ លើសពីនេះទៅទៀត ដំណើរការការិយាធិបតេយ្យ មានលក្ខណៈស្មុគស្មាញ និងត្រូវប្រើប្រាស់អស់ពេលច្រើន ធ្វើឱ្យពួកគេកាន់តែមានឱកាសច្រើនក្នុងការទាមទារថ្លៃឈ្នួលក្រៅផ្លូវការ បែបនេះ ។ ជារឿយៗ អាជីវករយល់ឃើញថា គេអាចសម្រេចការងារបានលឿនជាងអស់សាហ៊ុយតិចជាង ហើយងាយស្រួលជាង បើគេបង់ថ្លៃចំណាយក្រៅផ្លូវការបន្តិចបន្តួចទាំងនោះ បើប្រៀបធៀបទៅនឹងការចំណាយពេល និងកម្លាំងក្នុងការតតាំងជាមួយបែបបទការិយាធិបតេយ្យដ៏ស្មុគស្មាញ និងគ្មានតម្លាភាព ។

## ចំណាយក្រៅផ្លូវការខ្នាតធំ

នៅកម្រិតធំ គេបង់សំណូកម្តងៗមានទំហំធំ ក្នុងដំណើរការដេញថ្លៃ យកកិច្ចសន្យានៃលទ្ធកម្មសាធារណៈ ។ ជារឿយៗ គេគណនាសំណូកបែបនេះជាភាគរយនៃតម្លៃកិច្ចសន្យាលទ្ធកម្ម ហើយវាអាចមានតម្លៃខ្ពស់ ។ មានតែអាជីវកម្មមួយចំនួនតូចទេ ដែលបង់ចំណាយក្រៅផ្លូវការទាំងនេះ ព្រោះ ៩៩% នៃសហគ្រាសទាំងអស់ជាសហគ្រាសធុនតូច និងមធ្យម [២] ហើយពួកគេមានទំហំតូច មិនអាចចូលរួមដេញថ្លៃកិច្ចសន្យាលទ្ធកម្មសាធារណៈ បែបនោះបានទេ ។

ព្រឹត្តិប័ត្រនេះនឹងផ្តោតទៅលើបញ្ហាចំណាយក្រៅផ្លូវការខ្នាតតូចប៉ុណ្ណោះ ព្រោះ វាបង្កជាបញ្ហាផ្ទាល់ចំពោះអាជីវកម្មភាគច្រើន មិនមែនតែអាជីវកម្មធំៗ ។

## តើចំណាយក្រៅផ្លូវការខ្នាតតូច ប៉ះពាល់ដល់អាជីវកម្មយ៉ាងដូចម្តេច

ចំណាយក្រៅផ្លូវការខ្នាតតូចកំហិតលទ្ធភាពរីកចំរើនរបស់ក្រុមហ៊ុន នានាតាមហេតុផលមួយចំនួន ។ ទីមួយ វាបន្ថយលទ្ធភាពរកប្រាក់ចំណេញរបស់អាជីវកម្ម ព្រោះថា តាមធម្មជាតិរបស់វា ចំណាយក្រៅផ្លូវការគឺជាថ្លៃចំណាយបន្ថែម ដែលច្បាប់មិនបានទាមទារឱ្យអាជីវកម្មបង់ទេ ។ ទីពីរ ចំណាយក្រៅផ្លូវការបន្ថយលទ្ធភាពរបស់អាជីវកម្ម ក្នុងការប្រមើលទុកជាមុន ដែលធ្វើឱ្យអាជីវកម្មប្រព្រឹត្តទៅកាន់តែលំបាក និងចំណាយពេលកាន់តែច្រើន ។ ការបន្ថយលទ្ធភាពរកចំណេញ និងបរិយាកាសអាជីវកម្មដែលមិនអាចប្រមើលទុកជាមុនបាននេះធ្វើឱ្យអាជីវកម្មបាត់បង់ទំនុកចិត្ត ។

*ចំណាយក្រៅផ្លូវការធ្វើឱ្យថ្លៃដើមក្នុងការធ្វើអាជីវកម្មកើនឡើង ហើយធ្វើឱ្យអាជីវកម្មពិបាកនឹងរស់រានមានជីវិត និងប្រកួតប្រជែងលើទីផ្សារអន្តរជាតិ ។ ហេតុដូច្នេះហើយទើបសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកខ្លាំងទៅលើវិស័យកាត់ដេរ និងមិនអាចពង្រីកវិស័យផលិតកម្មឱ្យមានភាពសម្បូរបែប ដូចជាផលិតកម្មស្បែកជើង អេឡិចត្រូនិក និងការកែច្នៃម្ហូបអាហារ ។ល ។ មូលដ្ឋានសេដ្ឋកិច្ចដ៏ចង្អៀតនេះធ្វើឱ្យកម្ពុជាងាយរងគ្រោះដោយសារវិបត្តិពីខាងក្រៅ ហើយរារាំងមិនឱ្យគេអាចបង្កើតការងារចាំបាច់ ដែលមានកំរៃខ្ពស់ ។ ទាំងនេះនាំឱ្យមានភាពឥតការងារធ្វើ មានកំរិតខ្ពស់ក្នុងចំណោមយុវជនក្មេងៗ ដែលស្វែងរកការងារ ។*

**លោកស្រីNisha Agrawal នាយិកាគ្រប់គ្រង**
**ធនាគារពិភពលោក ប្រចាំនៅកម្ពុជា**

ចំណាយក្រៅផ្លូវការដែល គេត្រូវបង់ជាញឹកញយ រួមនិងដំណើរការការិយាធិបតេយ្យដ៏ស្មុគស្មាញនៅកម្ពុជា បង្កជាហេតុមួយជំរុញឱ្យអាជីវកម្មទាំងឡាយបន្តនៅធ្វើអាជីវកម្មទ្រង់ទ្រាយតូច និងក្រៅផ្លូវការ ។ នៅក្នុងរយៈពេលខ្លី យុទ្ធសាស្ត្រនេះជាយុទ្ធសាស្ត្រល្អ ព្រោះវាជួយឱ្យក្រុមហ៊ុនទាំងនោះជៀសវាងបានពីកាតព្វកិច្ចការិយាធិបតេយ្យ និងចំណាយក្រៅផ្លូវការដ៏ច្រើន ។ ប៉ុន្តែ ក្នុងរយៈពេលវែងវិញ វាកំហិតលទ្ធភាពធ្វើអាជីវកម្មរបស់ក្រុមហ៊ុន រារាំងលទ្ធភាពទទួលបានឥណទាន និងបង្អាក់ការរីកចំរើន ។[៣]

*សហគ្រាសធុនតូច និងមធ្យម ជួបបញ្ហាចំណាយក្រៅផ្លូវការ នៅពេលដែលពួកគេនាំចូលវត្ថុធាតុដើមសម្រាប់ផលិតកម្ម ។ សហគ្រាសធុនតូច និងមធ្យមត្រូវបង់ចំណាយក្រៅផ្លូវការដើម្បីសម្រួលការទទួលយកទំនិញពីមន្ត្រីគយ បើមិនដូច្នោះទេ គយនឹងពន្យារពេលក្នុងការបញ្ចេញទំនិញ ដែលការនេះធ្វើឱ្យសហគ្រាសធុនតូច និងមធ្យមខាតបង់ពេលវេលាជាច្រើន ។*

**លោក ហេង ហ៊ាង ប្រធានសមាគមឧស្សាហកម្មធុនតូច និងមធ្យម ភ្នំពេញ**

*នៅក្នុងខេត្តសៀមរាប ចំណាយក្រៅផ្លូវការធ្វើឱ្យអាជីវកម្ម ស្ទាក់ស្ទើរក្នុងការពង្រីកសកម្មភាពរបស់ខ្លួន ព្រោះកាលណាក្រុមហ៊ុនមានទំហំកាន់តែធំ មន្ត្រីកាន់តែច្រើន នឹងទាមទារថ្លៃឈ្នួលក្រៅផ្លូវការ ដែលរួមទាំងចំណាយក្រៅផ្លូវការលើពន្ធដារ សន្តិសុខ និងចំណាយផ្សេងៗទៀត ។ ថ្លៃដើមផលិតកម្មកាន់តែឡើងខ្ពស់ដោយសារការកើនឡើងនៃចំណាយទាំងនេះ ជាហេតុធ្វើឱ្យលទ្ធភាពប្រកួតប្រជែងរបស់អាជីវកម្មធ្លាក់ចុះ ។*

**លោក ផេង គង់ ប្រធានសភាពាណិជ្ជកម្ម ខេត្តសៀមរាប**

*ចំណាយក្រៅផ្លូវការប៉ះពាល់អាជីវកម្មខ្ញុំជាអវិជ្ជមាន ដោយធ្វើឱ្យចំណាយប្រតិបត្តិការកើនឡើងខ្ពស់ ។ ចំណាយក្រៅផ្លូវការ មិនត្រឹមតែប៉ះពាល់ដល់អាជីវកម្មសណ្ឋាគារប៉ុណ្ណោះទេ វាថែមទាំងប៉ះពាល់ដល់វិស័យទេសចរណ៍ទាំងមូល ។ ខ្ញុំជឿថា អាជីវកម្មផ្សេងទៀត ដូចជាភ្នាក់ងារនាំទេសចរ និងវិស័យដឹកជញ្ជូនតាមជើងអាកាសក៏បង់ចំណាយក្រៅផ្លូវការដែរ ។ ដើម្បីរក្សាប្រាក់ចំណេញរបស់ខ្លួន ភ្នាក់ងារទាំងនេះត្រូវតម្លើងថ្លៃដើម្បីទប់ចំណាយក្រៅផ្លូវការ ។ ដូច្នេះទេសចរដែលមកទស្សនាប្រទេសកម្ពុជាត្រូវបង់ថ្លៃខ្ពស់ ។*

**លោក ថាវ លីណា នាយកគ្រប់គ្រង សណ្ឋាគារ New York ភ្នំពេញ**

## កំរិតនៃចំណាយក្រៅផ្លូវការខ្នាតតូច នៅតាមខេត្តនៃប្រទេសកម្ពុជា

ការរកឃើញដ៏សំខាន់ របស់ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៦ គឺចំណាយក្រៅផ្លូវការ បង្កជាឧបសគ្គ ចំពោះការធ្វើអាជីវកម្ម ។ រូប១ បង្ហាញថា ចំណាយក្រៅផ្លូវការបង្កជាឧបសគ្គខ្លាំងសម្រាប់អាជីវកម្មក្នុងខេត្ត ដែលមានសកម្មភាពសេដ្ឋកិច្ចច្រើនដូចជាក្រុងព្រះសីហនុ ភ្នំពេញ ខេត្តសៀមរាប និងកណ្តាល ។

---

[២] រាជរដ្ឋាភិបាលកម្ពុជា អនុគណៈកម្មាធិការសហគ្រាសធុនតូច និង មធ្យម (២០០៥) *ក្របខ័ណ្ឌអភិវឌ្ឍន៍ សហគ្រាសធុនតូច និង មធ្យម*

[៣] ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ *កម្ពុជានៅលើផ្លូវបំបែក*

## រូប ១: វិសាលភាពនៃឧបសគ្គដែលបង្កឡើងដោយចំណាយក្រៅផ្លូវការខ្នាតតូចចំពោះការធ្វើអាជីវកម្ម (នៅតាមខេត្ត)




*ប្រភព: ដកស្រង់ចេញពីពិន្ទុចំណាយក្រៅផ្លូវការ នៃការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តក្នុងប្រទេសកម្ពុជា*

### តើគេគួរធ្វើយ៉ាងណាដើម្បីកាត់បន្ថយចំណាយក្រៅផ្លូវការ

ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តក្នុងប្រទេសកម្ពុជា បានបង្ហាញឱ្យអោយឃើញថា ចំណាយក្រៅផ្លូវការចោទជាបញ្ហាយ៉ាងណាចំពោះអាជីវកម្ម ។ កិច្ចការចំពោះមុខ គឺត្រូវកាត់បន្ថយចំណាយក្រៅផ្លូវការទាំងនោះ ដើម្បីជួយឱ្យអាជីវកម្មតូចៗងាយស្រួលធ្វើអាជីវកម្ម ។ នេះមិនមែនជាការងាយទេ ប៉ុន្តែវិធីមួយដែលផ្ដល់ផលល្អ យោងតាមបទពិសោធន៍នៅប្រទេសដទៃទៀត គឺត្រូវបន្ថយកត្តានានាដែលធ្វើឱ្យមន្ត្រីទាមទារថ្លៃឈ្នួលក្រៅផ្លូវការទាំងនោះ និងកត្តាជំរុញឱ្យអាជីវករព្រមបង់តាមការទាមទារ ។

នៅប្រទេសកម្ពុជា មូលហេតុចំបងដែលបណ្ដាលឱ្យមន្ត្រីរដ្ឋាភិបាលទាមទារឱ្យអាជីវកម្មបង់ថ្លៃឈ្នួលក្រៅផ្លូវការនោះ គឺព្រោះតែមន្ត្រីនានា ទទួលបានប្រាក់បៀវត្សរ៍ទាបពេក ។ មន្ត្រីទាំងឡាយតែងនាំគ្នានិយាយជាធម្មតាទៅហើយថា ពួកគេទារសំណូកបន្តិចបន្តួចទាំងនោះ ដោយសារប្រាក់បៀវត្សរ៍របស់ពួកគេមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ចំណាយឡើយ ។[៤] ការកាត់បន្ថយចំណាយក្រៅផ្លូវការ នឹងលើកទឹកចិត្តឱ្យមានការគោរពបទបញ្ញត្តិនានាបានល្អជាងមុន ហើយប្រាក់ចំណូលរបស់ខេត្តនឹងកើនឡើង ។

*នៅប្រទេសកម្ពុជា មូលហេតុចំបងដែលធ្វើឱ្យមន្ត្រីរដ្ឋាភិបាលមានបំណងទាមទារសំណូកគឺ ប្រាក់ខែរបស់ពួកគេមិនគ្រប់គ្រាន់សម្រាប់ចំណាយដើម្បីរស់នៅ ។ ដូច្នេះដំណោះស្រាយមួយគឺត្រូវដោះស្រាយបញ្ហាតំឡើងប្រាក់ខែមន្ត្រីរាជការ ។*

លោក សេក បរិសុទ្ធ នាយកកម្មវិធី ប្រឆាំងអំពើពុករលួយ
Pact Cambodia

យុទ្ធសាស្ត្ររយៈពេលខ្លីដែលគេអាចអនុវត្តបានជាក់ស្តែង ហើយដែលខេត្តទាំងឡាយអាចយកទៅប្រើប្រាស់បាន ដើម្បីកាត់បន្ថយចំណាយក្រៅផ្លូវការ គឺត្រូវកែលំអនីតិវិធីរដ្ឋបាល ដើម្បីកាត់បន្ថយឱកាសសម្រាប់មន្ត្រីទាំងឡាយទារថ្លៃឈ្នួលក្រៅផ្លូវការ និងកាត់បន្ថយកត្តានានាដែលបណ្ដាលឱ្យអាជីវកម្មបង់ថ្លៃឈ្នួលក្រៅផ្លូវការដល់មន្ត្រីរាជការ ។ គេអាចកាត់បន្ថយចំណាយក្រៅផ្លូវការបានដោយធ្វើឱ្យបែបបទការិយាធិបតេយ្យខ្លី ងាយស្រួល និងមានតម្លាភាព ជាងមុន ។ បែបបទរដ្ឋបាលដែលមានប្រសិទ្ធិភាពខ្ពស់ជាងមុន មានន័យថាមន្ត្រីទាំងឡាយ មានឱកាសតិចក្នុងការទារថ្លៃឈ្នួលបន្ថែមផ្សេងៗ ហើយវាក៏ជួយឱ្យការផ្ដល់សេវាសាធារណៈប្រព្រឹត្តទៅបានលឿន និងល្អប្រសើរជាងមុន ។ ការងារមានតម្លាភាពជាងមុន មានន័យថា ក្រុមហ៊ុនទទួលបានព័ត៌មានច្បាស់លាស់ជាងមុន អំពីសិទ្ធិ និង ករណីយកិច្ចរបស់ពួកគេ អំពីសេវា និង ថ្លៃឈ្នួលនានាដែលរដ្ឋាភិបាលកំណត់ ។ ឧទាហរណ៍ នៅទីក្រុងឡាប៉ាស នៃប្រទេសបូលីវី ការបង្ហាញព័ត៌មានអំពីបែបបទការងារចាំបាច់ ក្នុងដំណើរការរដ្ឋបាលនៅលើវិបសាយបានធ្វើព័ត៌មាន មានតម្លាភាព ហើយអាជីវកម្មអាចទទួលបានព័ត៌មាននោះបានកាន់តែច្រើនជាងមុន ។[៥]

*ក្រសួងពាណិជ្ជកម្មបានចូលរួមចំណែកយ៉ាងច្រើនក្នុងការកាត់បន្ថយនីតិវិធីក្នុងការចុះបញ្ជីអាជីវកម្ម និងកាត់បន្ថយចំណាយក្រៅផ្លូវការ ដូចជាយើងបានចេញប្រកាសលេខ១៦៣ ដែលកំណត់ឱ្យបញ្ចុះតម្លៃនៃការចុះបញ្ជីអាជីវកម្មមកត្រឹម ១៧៧ ដុល្លារ ។ យើងបានផ្សព្វផ្សាយការចុះតម្លៃយ៉ាងទូលំទូលាយឱ្យអាជីវករទាំងឡាយបានដឹង ។ ជាលទ្ធផល ការណ៍នេះនាំឱ្យចំណាយក្រៅផ្លូវការក្នុងការចុះបញ្ជីអាជីវកម្មធ្លាក់ចុះ ព្រោះក្រុមហ៊ុនទាំងឡាយដែលមានបំណងចង់ចុះបញ្ជីអាជីវកម្ម បានយល់ដឹងច្រើនអំពីតម្លៃផ្លូវការនៃការចុះបញ្ជី ។*

*ប្រហែលជាអាជីវករជាច្រើន មិនទាន់យល់ដឹងច្បាស់លាស់អំពីការចំណាយផ្សេងៗទៀត និងសំណុំឯកសារបែបបទផ្សេងៗដែលត្រូវបំពេញក្នុងការចាប់ផ្ដើមអាជីវកម្មទាំងមូល ដែលរួមទាំងការបង់ពន្ធប៉ាតង់ ការសុំអាជ្ញា*

[៤] វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (២០០៦) *ការវាយតំលៃអំពើពុករលួយ នៅក្នុងផ្នែកឯកជននៃប្រទេសកម្ពុជា*
[៥] សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ-IFC (២០០៥) *ការសម្រួលបែបបទអាជីវកម្ម នៅថ្នាក់ខេត្ត*

*បណ្ណពីក្រសួងពាក់ព័ន្ធផ្សេងៗទៀត ។ ដូចជាករណីការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មដែរ ប្រសិនបើអាជីវករយល់ដឹងអំពីចំណាយតាមផ្លូវច្បាប់ នោះវានឹងជួយឱ្យគេកាត់បន្ថយចំណាយក្រៅផ្លូវការបាន ។ ដូច្នេះ ជាយុទ្ធសាស្ត្រ គេគួរតែបង្កើនតម្លាភាព ដែលនេះមានន័យថា គេគួរផ្សព្វផ្សាយទៅដល់អាជីវករឱ្យបានទូលំទូលាយជាងមុន អំពីការបង់ប្រាក់ជាផ្លូវការ និងសំណុំបែបបទឯកសារដែលចាំបាច់ក្នុងការចាប់ផ្ដើមអាជីវកម្មទាំងមូល ។*

**ឯកឧត្តម ម៉ៅ ថូរ៉ា អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម**

នៅប្រទេសកម្ពុជា ការកែសម្រួល និងការកែលំអបែបបទការិយាធិបតេយ្យ ទំនងជាជំហានដ៏មានប្រសិទ្ធិភាពមួយ ដើម្បីកាត់បន្ថយចំណាយក្រៅផ្លូវការ ។ បច្ចុប្បន្ននេះ នីតិវិធីការិយាធិបតេយ្យជាច្រើន មានលក្ខណៈស្មុគស្មាញ បង្កការលំបាកច្រើន និងមិនសូវមានតម្លាភាពទេ ។ ឧទាហរណ៍ ការបើកអាជីវកម្ម គឺជាការងារដ៏ស្មុគស្មាញមួយ ដែលទាមទារឱ្យគេត្រូវជួបស្ថាប័នរដ្ឋាភិបាលនានាជាច្រើនដង បំពេញបែបបទការិយាធិបតេយ្យជាច្រើន និងមានសេចក្ដីណែនាំជាលាយលក្ខអក្សរតិចតួចពេក ស្ដីពីថ្លៃចំណាយ ឬបែបបទការិយាធិប្បតេយ្យ ។ នៅតាមដំណាក់កាលនីមួយៗនៃដំណើរការការិយាធិបតេយ្យ គេត្រូវទាក់ទងនឹងមន្ត្រីផ្សេងៗគ្នា ហើយនេះគឺជាឱកាសថ្មីៗសម្រាប់មន្ត្រីទារថ្លៃឈ្នួលក្រៅផ្លូវការបន្ថែម ។ ថ្វីបើការកែសម្រួល និងការកែលំអនីតិវិធីរដ្ឋបាលបែបនេះមិនអាចរារាំងចំណាយក្រៅផ្លូវការបានទាំងស្រុងក្ដី គេអាចធ្វើឱ្យមានការកែប្រែជាវិជ្ជមាននៅកម្ពុជា តាមរយៈការកាត់បន្ថយឱកាសទារថ្លៃឈ្នួលទាំងនោះ និងកត្តានានា ដែលជំរុញឱ្យក្រុមហ៊ុន បង់ថ្លៃឈ្នួលនោះ ។

*ក្នុងឆ្នាំ២០០៤ រដ្ឋាភិបាលអនុម័ត កម្មវិធីកែទម្រង់ ១២ ចំណុច លើការសម្រួលពាណិជ្ជកម្ម ដើម្បីកាត់បន្ថយចំណាយក្រៅផ្លូវការទាំងនេះ ។ ការរីកចម្រើនទៅមុខនៃកំណែទម្រង់ទាំងនេះទទួលបានលទ្ធផលមិនល្អទាំងស្រុងនៅឡើយទេ ហើយរដ្ឋាភិបាលគួរតែបង្កើនល្បឿនកំណែទម្រង់នេះឱ្យបានឆាប់ ។*

**លោកស្រី Nisha Agrawal នាយិកាគ្រប់គ្រង ធនាគារពិភពលោក ប្រចាំនៅកម្ពុជា**

## ផលប្រយោជន៍នៃការកាត់បន្ថយចំណាយក្រៅផ្លូវការ

ការកាត់បន្ថយចំណាយក្រៅផ្លូវការ ផ្ដល់ផលប្រយោជន៍ដល់អាជីវកម្ម រដ្ឋាភិបាល និងសេដ្ឋកិច្ចកម្ពុជា ដោយធ្វើឱ្យបរិយាកាសអាជីវកម្មល្អប្រសើរឡើង ។

បរិយាកាសអាជីវកម្មល្អ ធ្វើឱ្យផ្នែកឯកជនរីកចំរើន និង បង្កើតការងារបានកាន់តែច្រើនឡើង ។ ការវិភាគស្ថិតិរបស់ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តក្នុងប្រទេសកម្ពុជា បង្ហាញថា បើសិនជា រដ្ឋាភិបាលថ្នាក់ខេត្តអាចកាត់បន្ថយចំណាយក្រៅផ្លូវការបាន នោះក្រុមហ៊ុនទាំងឡាយនឹងពង្រីកអាជីវកម្មរបស់ខ្លួន និងជួលបុគ្គលិកច្រើនជាងមុន ។ កាលណាផ្នែកឯកជនរីកចម្រើន វានឹងជួយជំរុញឱ្យមានកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ។

*ប្រសិនបើរដ្ឋាភិបាលថ្នាក់ខេត្តកាត់បន្ថយចំណាយក្រៅផ្លូវការបានមួយពិន្ទុលើពិន្ទុបរិយាកាសអាជីវកម្ម ការវិភាគស្ថិតិរបស់យើងបង្ហាញថា វានឹងបង្កើតការងារបន្ថែម ២១ % ដោយសារអាជីវកម្មនឹងពង្រីកសកម្មភាពរបស់ខ្លួន ហើយជួលបុគ្គលិកបន្ថែមទៀត ។*

**សាស្ត្រាចារ្យ Edmund Malesky ទីប្រឹក្សាបច្ចេកទេស គម្រោងការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត**

ផលប្រយោជន៍មួយទៀតនៃការកាត់បន្ថយថ្លៃចំណាយក្រៅផ្លូវការ គឺការលើកទឹកចិត្តឱ្យមានការគោរពបទបញ្ញត្តិច្រើនជាងមុន ។ បច្ចុប្បន្ន អាជីវកម្មច្រើនតែជៀសវាងមិនចង់ជួបពាក់ព័ន្ធជាមួយរដ្ឋាភិបាល ដើម្បីចៀសវាងការបង់ថ្លៃឈ្នួលក្រៅផ្លូវការ ។ ដូច្នេះ ការកាត់បន្ថយចំណាយក្រៅផ្លូវការនឹងបង្កើនការគោរពច្បាប់ និងពង្រឹងការអនុវត្តន៍ច្បាប់ ។

ចំពោះរដ្ឋាភិបាល ផលប្រយោជន៍ផ្ទាល់មួយនៃការកាត់បន្ថយចំណាយក្រៅផ្លូវការ គឺកំណើនប្រាក់ចំណូលរបស់រដ្ឋ ។ បែបបទរដ្ឋបាលមានតម្លាភាព និងងាយស្រួលជាងមុន ធ្វើឱ្យមានអាជីវកម្មផ្លូវការកាន់តែច្រើនជាងមុន ហើយប្រការនេះ មានន័យថា ប្រាក់ចំណូលរបស់រដ្ឋាភិបាលកើនឡើង ព្រោះអាជីវកម្មទាំងនោះចាប់ផ្ដើមបង់ពន្ធដារ និងថ្លៃឈ្នួលរដ្ឋបាលផ្សេងៗទៀត ។ នៅទីក្រុងដាគូប៉ាន នៃប្រទេសភីលីពីន ការកែលំអដំណើរការចុះបញ្ជីអាជីវកម្ម នាំឱ្យប្រាក់ចំណូលរបស់ទីក្រុងនេះកើនឡើងបាន ១៣% ។[៦] ដូចគ្នានេះដែរ នៅទីក្រុង ឡាប៉ាស នៃប្រទេសបូលីវី ការសម្រួល និងការកែលំអបែបបទចុះបញ្ជីអាជីវកម្ម នាំឱ្យចំនួនអាជីវកម្មដែលបានចុះបញ្ជីកើនឡើង ២០% ដែលមានន័យថា រដ្ឋាភិបាលទីក្រុងទទួលបានប្រាក់ចំណូលច្រើនជាងមុន ។[៧]

## ជំហានបន្ទាប់ទៀត

ថ្វីបើចំណាយក្រៅផ្លូវការជាបញ្ហាចោទធំមួយក្ដី ការកាត់បន្ថយវាមិនមែនជាការងាយស្រួលទេ និងទាមទារ ឱ្យរដ្ឋាភិបាលថ្នាក់ខេត្ត មានការប្ដេជ្ញាចិត្តមុតមាំ ។ គេអាចលុបបំបាត់ចំណាយក្រៅផ្លូវការបាន លុះណាតែគេ ដោះស្រាយបានទាំងស្រុង នូវរាល់កត្តានានាដែលបង្កឱ្យមានចំណាយក្រៅផ្លូវការនេះ ។

ក្នុងរយៈពេលខ្លី រដ្ឋាភិបាលថ្នាក់ខេត្ត អាចចាប់ផ្ដើមកាត់បន្ថយចំណាយក្រៅផ្លូវការទាំងនោះ ដោយបន្ថយបែបបទ ការងារការិយាធិបតេយ្យ និងកែសម្រួលប្រព័ន្ធទាំងឡាយឱ្យងាយជាងមុន ព្រមទាំងផ្ដល់ព័ត៌មានដល់បណ្ដាអាជីវកម្ម ឱ្យបានច្បាស់លាស់ជាងមុន ។ វិធានការបែបនេះពិតជាអាចធ្វើ ឱ្យសម្រេចបាន និងនាំឱ្យមានផលប្រយោជន៍ផ្ទាល់ ដល់អាជីវកម្ម រដ្ឋាភិបាល និងសេដ្ឋកិច្ចមូលដ្ឋាន ។ លើសពីនេះទៅទៀត វិធានការទាំងនេះនឹងធ្វើឱ្យគេជឿទុកចិត្តទៅលើរដ្ឋាភិបាល ព្រមទាំងបង្ហាញពី ការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការកែលំអការងាររបស់ខ្លួន ។

បច្ចុប្បន្ននេះ កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC-MPDF) កំពុងសហការជាមួយខេត្តមួយចំនួន ដើម្បីជួយសម្រួល និងកែលំអបែបបទរដ្ឋបាលដែលចាំបាច់សម្រាប់ចាប់ផ្ដើមអាជីវកម្ម ។

[៦] សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ-IFC (២០០៥) *ការសម្រួលបែបបទអាជីវកម្ម នៅថ្នាក់ខេត្ត*

[៧] សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ-IFC (២០០៥) *ការសម្រួលបែបបទអាជីវកម្ម នៅថ្នាក់ខេត្ត*


រក្សាសិទ្ធិ MPDF 2007
Publisher: MPDF No. 70, Norodom Blvd., Phnom Penh
Tel: (855)-23-210-922 Fax: (855)-23-215-157
E-mail: shor@ifc.org Website: www.mpdf.org
Layout by: Kea Kunthea
Printed by: MAKARA Printing House